# វិធីសាស្ត្រគ្រប់គ្រង
# ផ្កាម្លិះ
## ក្រោយពេលប្រមូលផល




មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
Centre d'Etude et de Développement Agricole Cambodgien

វិទ្យាស្ថានអន្តរជាតិដើម្បីស្តារជនបទឡើងវិញ
International Institute of Rural Reconstruction



ឧបត្ថម្ភដោយ មូលនិធិ ម៉ាកណាយ
**Funded by McKnight Foundation**


### ១) ការប្រមូលផល

ក្រោយដាំបានរយះពេល ៦ ខែ វាអាចចេញផ្កាឱ្យយើងបេះបាន។ ចំពោះការបេះ យើងមិនចាំបាច់ទុកឱ្យរីកទាន់ទេ គឺជាទូទៅយើងសំគាល់ថា :

- ល្អមនឹងបេះនៅពេលផ្កានោះស្ទើររីក តែពុំទាន់បែកមាត់ចាបទេ ហើយពណ៌របស់វាសំគាល់ឃើញថាសភ្លឺថ្លា។
- ការបេះផ្កាម្លិះយោងទៅតាមតំរូវការជាក់ស្តែង បើផ្កានោះត្រូវការយកមកប្រើប្រាស់ភ្លាមៗ (ចាក់ភួង) គឺបេះមិនឱ្យជាប់គល់ទងទេ។ ប៉ុន្តែ បើយើងមានបំណងរក្សាទុកយូរ ការបេះត្រូវបេះទាំងគល់ទង។ ធ្វើយ៉ាងនេះអាចរក្សាទុកបានដោយពុំបាត់គុណភាពឡើយ ត្រូវកាត់ផ្កាថ្មៗ កុំឱ្យបែកផ្កា។
- ពេលវេលានៃការប្រមូលផល ត្រូវធ្វើឡើងពេលអាកាសធាតុត្រជាក់ ហើយស្រស់ទឹក ឬទឹកសន្សើមធ្វើយ៉ាងណាឱ្យផ្កាអាចរក្សាក្លិន និងមានគុណភាពល្អបានយូរ។ យកល្អចាប់ពីម៉ោង ៨ ព្រឹកឡើងទៅ។



## ២) ការជ្រើសរើសគុណភាពផ្កា

ក្រោយពីប្រមូលផលពីដើមរួច គេត្រូវជ្រើសរើស បែងចែកផ្កាជា ២ ប្រភេទផ្សេងគ្នា : ប្រភេទទី ១ សំរាប់ចាក់ភួង (ភួងដៃ ភួងក និងភួងធំៗ សំរាប់ពិធីបុណ្យ ការ និងថ្វាយព្រះជាដើម) និងលេខ ២ (ផ្ការីក និងផ្កាតូចៗ មិនអាចចាក់ភួងបាន) សំរាប់លក់ឱ្យគេធ្វើតែ (ភេសជ្ជៈ)។



## ៣) ការចាក់ភួងផ្កាសំរាប់លក់

ចំពោះផ្កាម្លិះមុនពេលចាក់ភួង យើងដាក់ត្រាំទឹក ១០ ទៅ ១៥ នាទីសិន ដើម្បីឱ្យងាយស្រួលក្នុងការចាក់។ ប៉ុន្តែតាមបទពិសោធន៍កន្លងមក ការត្រាំផ្កាក្នុងទឹកត្រជាក់មុនយកទៅចាក់ជាភួង ផ្កានេះទុកពុំបានយូរបណ្តាលឱ្យវាឆាប់ជាំ និងរលួយ។ បើខានមិនបាន យកល្អយើងលាងជាមួយទឹកកក ដើម្បីឱ្យវារឹងងាយស្រួលចាក់ ហើយអាចកាត់បន្ថយជាតិទឹកនៅក្នុងខ្លួនរបស់វា។





## ៤) ការវេចខ្ចប់ និងដឹកជញ្ជូន

ផលផ្កាម្លិះ ក្រោយពីប្រមូលត្រូវធ្វើយ៉ាងណាវេចខ្ចប់ឱ្យបានល្អ បើពុំដូច្នោះទេ គឺវារីក ឬរលួយខូចអស់តែម្តង។ យើងត្រូវយកផ្កាខ្ចប់ក្នុងស្បោងប្លាស្ទិក រួចក្លាស្សេទឹកកក ដោយធ្វើយ៉ាងណាចង ឬរុំវាឱ្យបានជិតល្អមុននឹងដាក់ក្លាស្សេក្នុងធុង។ ចំពោះផ្កាដែលចាក់ចង្កាក់ ឬភួងរួចហើយ យើងត្រូវក្លាស្សេជាមួយទឹកកកផ្ទាល់តែម្តង ហើយធ្វើយ៉ាងណាកុំឱ្យមានទឹកក្នុងធុងឱ្យសោះ នាំឱ្យវាជ្រាបចូលដល់ផ្កា ដែលអាចធ្វើឱ្យផ្ការលួយបាន។

ឯការដឹកជញ្ជូនវិញ គឺយកធុងផ្កាកំពុងក្លាស្សេទៅ ដាក់លើម៉ូតូ រ៉ឺម៉ក ឬឡានតែម្តង។ តែធ្វើយ៉ាងណាដឹកនៅពេលត្រជាក់ ដើម្បីកុំឱ្យទឹកកកឆាប់រលាយ នាំឱ្យប៉ះពាល់ដល់ផ្កា។







## ៥) ការរក្សាទុកផ្កាម្លិះ

ក្នុងការថែរក្សាទុកផ្កាម្លិះឱ្យបានយូរ យើងត្រូវ :

- ចាក់ជាភួង រួចយកទៅក្លាស្សេក្នុងទឹកកក។ ការធ្វើរបៀបនេះ អាចរក្សាទុកបានពី ៤ ទៅ ៦ ថ្ងៃ តែនៅមានជាំ ឬរលួយខ្លះ ឯគុណភាពផ្កានៅល្អ អាចលក់បាន
- ប្រើស្បោងប្លាស្ទិកធម្មតា ដែលមានចំណុះពីកន្លះគីឡូទៅ ២ គីឡូក្រាម ច្រកផ្កាម្លិះខ្ចប់ឱ្យជិតល្អ រួចក្លាស្សេក្នុងធុងទឹកកក ធ្វើយ៉ាងណាកុំឱ្យជ្រាបទឹកចូលក្នុងស្បោង។ ធ្វើរបៀបនេះ យើងអាចរក្សាទុកបានរយៈពេលជិត ២ អាទិត្យ ដោយមានក្លិន និងគុណភាពល្អប្រសើរ។



---

**កសិករមានបទពិសោធន៍ និង បានធ្វើការសាកល្បង**

នេត សុខ ញឿង វណ្ណា ពត បញ្ញារិទ្ធិ ជា សារុផ ពត ខេត្ត